កុមាររៀន
កុមារចេះ
ក ១ ២៣

# ដប់ពីរខែ



**កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូងនៃក្រសួងអប់រំ យុវជន និងកីឡា**

រឿង ៖ **ដប់ពីរខែ**
និពន្ធដោយ ៖ **អុន ងួន**
វិចិត្ររូបភាពដោយ ៖ **ស៊ិន ធួកណា**

សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយក្រោមអាជ្ញាប័ណ្ណ CC BY-SA ។

សៀវភៅនេះត្រូវបានបង្កើតឡើងសម្រាប់កម្មវិធីកុមាររៀនកុមារចេះ ដែលជាកម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីជំនួយពីពលរដ្ឋអាមេរិក។

ដើម្បីស្វែងរកសៀវភៅនេះនិងសៀវភៅដទៃទៀតសម្រាប់កុមារ លោកអ្នកអាចចូលទៅកាន់ទំព័រហ្វេសប៊ុកកុមាររៀនកុមារចេះ

www.facebook.com/123komar




ឬគេហទំព័រ តោះអាន ឬទាញយកកម្មវិធីបណ្ណាល័យឌីជីថលតោះអាន

www.LetsReadAsia.org

ថ្ងៃទី០១ ខែមករា ជាថ្ងៃចូលឆ្នាំសកល។
យើងបានឈប់សម្រាកមួយថ្ងៃ។



ខែកុម្ភៈមានតែ២៨ ឬ២៩ថ្ងៃប៉ុណ្ណោះ។
នៅឆ្នាំខ្លះយើងប្រារព្ធពិធីបុណ្យមាឃបូជា
នៅក្នុងខែកុម្ភៈ។



ថ្ងៃទី១១ ខែមីនា ជាថ្ងៃទិវាជាតិអំណាន។
ថ្ងៃទី០៨ ខែមីនា ជាថ្ងៃទិវាអន្តរជាតិនារី។



យើងប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ នៅពាក់កណ្តាលខែមេសា។

ខែមេសា គឺជាខែដែលមានអាកាសធាតុក្តៅជាងគេបំផុត។



យើងប្រារព្ធពិធីបុណ្យច្រត់ព្រះនង្គ័ល នៅខែ ឧសភា។ ខែឧសភា ភ្លៀងចាប់ផ្ដើមធ្លាក់ជា លើកដំបូង។



នៅខែមិថុនា កសិករកំពុងរវល់ធ្វើស្រែ។
ថ្ងៃទី០១ ខែមិថុនា ជាទិវាកុមារអន្តរជាតិ។



នៅចុងខែកក្កដា ទឹកចាប់ផ្ដើមរីង ក្មេងៗ
នាំគ្នាចាប់ត្រីក្នុងវាលស្រែ។
ក្មេងៗលេងងូតទឹកភ្លៀង។



នៅចុងខែសីហា សិស្សសាលាចាប់ផ្ដើម
ឈប់សម្រាកវិស្សមកាលធំ។



នៅឆ្នាំខ្លះ យើងប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌនៅខែកញ្ញា។ ភ្លៀងចាប់ផ្ដើមធ្លាក់ច្រើន និងអាចមានទឹកជំនន់ នៅខែកញ្ញា។ នៅចុងខែកញ្ញា ជាទិវាមនុស្សថ្លង់ពិភពលោក។



នៅខែតុលា យើងមានពិធីបុណ្យកឋិនទាន នៅតាមវត្ត។ នៅខែតុលា កុមារចាប់ផ្ដើមចុះឈ្មោះចូលរៀនវិញ ។



នៅឆ្នាំខ្លះ យើងប្រារព្ធពិធីបុណ្យអុំទូក
អកអំបុក និងសំពះព្រះខែ នៅខែវិច្ឆិកា។
នៅដើមខែវិច្ឆិកា សិស្សសាលាចាប់ផ្ដើម
ចូលរៀនឆ្នាំសិក្សាថ្មី។



ខែផល្គុន គឺជាខែដែលមានខ្យល់បក់ និងល្ហើយ ជាងខែផ្សេងៗ។ ខែផល្គុន ជារដូវច្រូតកាត់ប្រមូលផលស្រូវ។ នៅថ្ងៃទី០៣ ខែផល្គុន ជាថ្ងៃទិវាជនពិការអន្តរជាតិ។ អូ! ជិតដល់ពេលចូលខែមករា ចូលឆ្នាំថ្មីទៀតហើយ។



# សំណួរ

១. តើខែណាដែលមានតែ២៨ថ្ងៃ ឬ២៩ថ្ងៃ?

២. តើខែណាដែលមានអាកាសធាតុក្តៅជាងគេ?

៣. តើខែណាដែលគេប្រារព្ធពិធីបុណ្យអុំទូក
អកអំបុក និងសំពះព្រះខែ?

៤. តើកូនចូលចិត្តខែណាជាងគេ? ហេតុអ្វី?



សិស្សថ្នាក់ទី១ ដែលកំពុងរៀននៅចុងឆ្នាំសិក្សា និង សិស្សថ្នាក់ទី២ ដែលកំពុងរៀននៅដើមឆ្នាំសិក្សា អាច អានសៀវភៅរឿងនេះ ដើម្បីជាការហ្វឹកហាត់អំណាន បន្ថែម ដោយមិនចាំបាច់មានអ្នកជួយឡើយ។ ទោះយ៉ាងណា សិស្សក៏អាចអានសៀវភៅរឿងនេះ ជាមួយគ្រូបានដែរ ដោយពួកគេអាចមើល និងនិយាយ អំពីរូបភាពនៅក្នុងសៀវភៅរឿងនេះហើយអានពាក្យ និងតួអក្សរដែលពួកគេស្គាល់។
ដរាបណាសិស្សចាប់ផ្ដើមអានសៀវភៅកាន់តែឆាប់ គឺ កាន់តែល្អសម្រាប់ពួកគេ។

កម្មវិធីជាតិស្ដីពីការសិក្សាកម្រិតថ្នាក់ដំបូង
នៃក្រសួងអប់រំ យុវជន និងកីឡា

បោះពុម្ពឆ្នាំ ២០២០